ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 02-Apr-2015, 14:20
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជតក |
| ដាក់ទៅ | : | អង្គជំនុំជម្រះតុលាការកំពូល |
| ថ្ងៃដាក់ | : | ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះតុលាការកំពូល: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រ និងពេលវេលា ដើម្បីឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១

---

**អ្នកដាក់ឯកសារ:**
**សហព្រះរាជអាជ្ញា:**
លោកស្រី ជា លាង
លោក Nicholas KOUMJIAN

**អ្នកទទួលឯកសារ:**
**អង្គជំនុំជម្រះតុលាការកំពូល:**
ចៅក្រម គង់ ស្រីម, ប្រធាន
ចៅក្រម A. KLONOWIECKA-MILART
ចៅក្រម សោម សិរីវឌ្ឍ
ចៅក្រម C. N. JAYASINGHE
ចៅក្រម ម៉ុង មុន្នីចរិយា
ចៅក្រម យ៉ា ណារិន
ចៅក្រម Florence Ndepele MUMBA

**ចម្លងជូន:**
**សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:**
លោក ពេជ អង្គ
លោកស្រី Marie GUIRAUD

**ជនជាប់ចោទ:**
នួន ជា
ខៀវ សំផន

**មេធាវីការពារក្តីជនជាប់ចោទ:**
លោក សុន អរុណ
លោក Victor KOPPE
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN

**មេធាវីប្រចាំការ:**
លោកស្រី ទូច វល័ក្ស
លោក Calvin SAUNDERS

# I. សេចក្ដីផ្ដើម និង ប្រវត្តិនីតិវិធី

1. ដោយអនុលោមតាមវិធាន៣៩(៤)[1] នៃវិធានផ្ទៃក្នុង និងមាត្រា៥.៤ និង៨.២[2] សហព្រះរាជអាជ្ញា សូមគោរពស្នើសុំការអនុញ្ញាតពីអង្គជំនុំជម្រះតុលាការកំពូល ("អង្គជំនុំជម្រះ") បន្ថែម១៨០ទំព័រ និង ២១ថ្ងៃ ទាក់ទងនឹងការដាក់ចម្លើយតបរួមរបស់ខ្លួន ("ចម្លើយតបរួម") ទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់ នួន ជា និង ខៀវ សំផន ("សារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ")។

2. នៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៤ សាលក្រមលើសំណុំរឿង០០២/០១ ត្រូវបានដាក់ជាភាសាខ្មែរ អង់គ្លេស និងបារាំង[3]។ នៅថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ នួន ជា និង ខៀវ សំផន (រួមគ្នាហៅថា "ភាគីប្ដឹងសាទុក្ខ") បានដាក់សេចក្ដីជូនដំណឹងរបស់ពួកគាត់ស្ដីពីការប្ដឹងសាទុក្ខប្រឆាំងនឹង សាលក្រមនោះ[4]។ នៅថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៤ គឺ ២០សប្ដាហ៍ និង៤ថ្ងៃ ក្រោយពេលដែល គេអាចរក សាលក្រមនោះបានទាំងបីភាសា ភាគីប្ដឹងសាទុក្ខបានដាក់សារណាបណ្ដឹងសាទុក្ខរបស់ពួកគាត់ ដែលសរុបរួមគ្នាមាន៤៨០ទំព័រ[5]។

3. នៅមុនការដាក់សារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ សហព្រះរាជអាជ្ញាបានស្វែងរកសុំការ អនុញ្ញាតដើម្បីដាក់ចម្លើយតបរួមមួយ ដែលមានប្រវែងស្មើនឹងប្រវែងរួមបញ្ចូលគ្នានៃសារណា បណ្ដឹងសាទុក្ខរបស់ជនជាប់ចោទ និងបានស្នើសុំកាលបរិច្ឆេទកំណត់មួយចំនួន៩០ថ្ងៃ សម្រាប់ ចម្លើយតបរួម នៅបន្ទាប់ពីកាលបរិច្ឆេទដែលសារណាបណ្ដឹងសាទុក្ខរបស់ជនជាប់ចោទត្រូវបាន ដាក់ជាពីរភាសា[6]។ អង្គជំនុំជម្រះបានអនុញ្ញាតលើការស្នើសុំរបស់សហព្រះរាជអាជ្ញា ឲ្យដាក់

---

[1] វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។

[2] សេចក្ដីណែនាំអនុវត្តសម្រាប់ដាក់ឯកសារនៅចំពោះមុខ អវតក, អវតក/០១/២០០៧/វិសោធនកម្មលើកទី៨។

[3] **E313**, សាលក្រម, ៧ សីហា ២០១៤។

[4] **E313/1/1**, សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១, ២៩ កញ្ញា ២០១៤។ **E313/2/1**, សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១, ២៩ កញ្ញា ២០១៤។

[5] **F16**, បណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង០០២/០១, ២៩ ធ្នូ ២០១៤។ **F17**, សារណាបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០១, ២៩ ធ្នូ ២០១៤។

[6] **F7/1**, ចម្លើយតប និងសំណើរបស់សហព្រះរាជអាជ្ញាលើបណ្ដឹងសាទុក្ខសំណុំរឿង០០២/០១ និងសុំបន្ថែមចំនួនទំព័រ និងពេលវេលាកំណត់សម្រាប់ធ្វើសារណាតប,១៦ តុលា ២០១៤, កថាខណ្ឌ ១៥-១៦, ២៣-២៤។

ចម្លើយតបរួមមួយដែលមានចំនួន២៨០ទំព័រ[7] (គឺ២០០ទំព័រ តិចជាងសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទរួមបញ្ចូលគ្នា[8]) ព្រមទាំងដាក់កាលបរិច្ឆេទកំណត់ក្នុងការដាក់ចម្លើយតបរួម ៣០ថ្ងៃ បន្ទាប់ពីការដាក់សំណៅជាភាសាខ្មែរចុងក្រោយ នៃសារណាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ[9]។

4. នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ការបកប្រែជាភាសាខ្មែរនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ត្រូវបានដាក់[10]។ ហេតុដូច្នេះ គឺបង្កើតបានជាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៥ ជាកាលបរិច្ឆេទបច្ចុប្បន្នសម្រាប់ការដាក់ចម្លើយតបរួម។

## II. អំណះអំណាង

### *ក. ការបន្ថែមចំនួនទំព័រ*

*(១) ការតម្រូវឱ្យសហព្រះរាជអាជ្ញា ដាក់ចម្លើយតបរួម តិចជាង ៤៦០ទំព័រ អាចធ្វើឱ្យមានការប៉ះពាល់ដល់ភាពសុចរិតនៃអំណះអំណាងទាំងឡាយរបស់សហព្រះរាជអាជ្ញា ហើយដូច្នេះ អាចផ្ទុយទៅនឹងផលប្រយោជន៍នៃយុត្តិធម៌*

5. បច្ចុប្បន្ន នួន ជា និង ខៀវ សំផន បញ្ចូលគ្នា មានច្រើនទំព័រជាងសហព្រះរាជអាជ្ញា រហូតដល់ទៅ ៧០ភាគរយ សម្រាប់ធ្វើអំណះអំណាងរបស់ពួកគាត់នៅក្នុងបណ្តឹងសាទុក្ខនេះ គឺ៤៨០ទំព័រ ប្រៀបធៀបនឹង២៨០ទំព័រ។ ចំនួន២០០ទំព័រខុសគ្នាបែបនេះ គឺមិនមានតុល្យភាពទេ ដែលសូម្បីតែការព្រាងដោយជំនាញ និងផ្តល់ប្រយោជន៍គ្រប់គ្រាន់ អាចជំនះបានប្រកបដោយសមស្រប ក្នុងការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះសារណាបណ្តឹងសាទុក្ខទាំងពីរ[11]។

---

[7] **F9**, សេចក្តីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតប, ៣១ តុលា ២០១៤ ("សេចក្តីសម្រេចលើរយៈពេល និងចំនួនទំព័រកំណត់"), កថាខណ្ឌ ១៧។

[8] ភាគីប្តឹងសាទុក្ខនានាត្រូវបានអនុញ្ញាតពីដំបូង សរុបបញ្ចូលគ្នាចំនួន ៤២០ទំព័រ (ម្នាក់ៗ ២១០ទំព័រ) សម្រាប់សារណាបណ្តឹងសាទុក្ខរបស់ពួកគាត់។ សេចក្តីសម្រេចលើរយៈពេល និងចំនួនទំព័រកំណត់, កថាខណ្ឌ ១៧។ នួន ជា ក្រោយមកត្រូវបានអនុញ្ញាតឱ្យបន្ថែមរហូតដល់ទៅ ២៧០ទំព័រ បន្ទាប់ពីការស្នើសុំលើបញ្ហានេះ។

[9] សេចក្តីសម្រេចលើរយៈពេល និងចំនួនទំព័រកំណត់, កថាខណ្ឌ ២១។

[10] **F17**, សារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង០០២/០១, ២៩ ធ្នូ ២០១៤, សំណៅជាភាសាខ្មែរត្រូវបានដាក់នៅថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥។

[11] នេះគឺជាការពិតជាពិសេសទាក់ទងនឹងបញ្ហាដូចបានពិភាក្សាខាងក្រោម ទាក់ទងនឹងសេចក្តីថ្លែងសំអាងនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។

6. ទោះបីជានៅមានការងារសំខាន់ៗដែលត្រូវធ្វើយ៉ាងណាក៏ដោយ ក៏ឥឡូវនេះ សហព្រះរាជអាជ្ញាមានសេចក្តីព្រាងដំបូងនៃផ្នែកសំខាន់ៗនៃចម្លើយតបរួមរបស់ខ្លួនរួចហើយ។ ផ្អែកលើសេចក្តីព្រាងដែលរហូតមកដល់ពេលនេះត្រូវបានបញ្ចប់រួចហើយ សហព្រះរាជអាជ្ញាប៉ាន់ស្មានថាសេចក្តីព្រាងទាំងស្រុងដំបូងនៃចម្លើយតបរួមនេះ នឹងអាចមានប្រមាណជា ៥៥០ទំព័រ។ ក្នុងអំឡុងពេលនៃដំណើរការព្រាង និងបន្ទាប់ពីបញ្ចប់នូវសេចក្តីព្រាងដំបូងនេះ សហព្រះរាជអាជ្ញានឹងចាត់ការលើដំណើរការពិនិត្យទាំងស្រុង ដែលបានយល់ជ្រួតជ្រាបដោយភាពចាំបាច់ ក្នុងការធ្វើឲ្យមានតុល្យភាពរវាងប្រសិទ្ធិផលផ្នែកច្បាប់ និងករណីយកិច្ចរបស់ខ្លួនក្នុងការបង្ហាញរឿងក្តី[12]។

7. សហព្រះរាជអាជ្ញាមានបំណងកាត់បន្ថយសេចក្តីព្រាងដំបូងដែលមានចំនួន៥៥០ទំព័រនេះ ឲ្យមកនៅត្រឹម៤៦០ទំព័រវិញ ដែលជាការកាត់បន្ថយមួយដែលមានចំនួន៩០ទំព័រ ឬច្រើនជាង១៥ភាគរយ។ សហព្រះរាជអាជ្ញាជឿជាក់ថា ការកាត់បន្ថយទាំងឡាយណាដែលហួសពីនេះ មុខជានឹងតម្រូវឲ្យសហព្រះរាជអាជ្ញា ចាំបាច់ត្រូវតែទម្លាក់ចោលនូវចម្លើយតបនានាលើទឡ្ហីករណ៍សំខាន់ៗនៃបណ្តឹងសាទុក្ខ ក្នុងគោលបំណងរក្សាទុកនូវភាពទាក់ទងគ្នា និងភាពសុចរិតនៃចម្លើយតបរបស់ខ្លួន លើបញ្ហានានាដែលមានលក្ខណៈពិបាក និងស្មុគស្មាញ ដែលបានលើកឡើងដោយ ភាគីប្តឹងសាទុក្ខ។ សហព្រះរាជអាជ្ញា សូមជូនសេចក្តីសន្និដ្ឋានថា ការតម្រូវឲ្យកាត់ទៅតាម លក្ខណៈនេះ អាចមិនមែនជាផលប្រយោជន៍នៃយុត្តិធម៌ ផលប្រយោជន៍នៃអង្គជំនុំជម្រះនេះ ឬមិនមែនជាផលប្រយោជន៍របស់សាធារណជន និងជនរងគ្រោះទាំងឡាយនោះទេ ដែលពួកគេសមនឹងបានទទួលបានការដឹងឮពីចម្លើយតបនានារបស់សហព្រះរាជអាជ្ញា ទៅនឹងការជំទាស់នានា ដែលមេធាវីការពារក្តីបានលើកឡើងប្រឆាំងនឹងសាលក្រម[13]។

---

[12] *សូមអាន* **F13/2,** សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប, ១១ ធ្នូ ២០១៤, កថាខណ្ឌ ១៥ (ទំព័រកំណត់ "ត្រូវតែធ្វើឡើងដោយស្របទៅនឹងតម្រូវការចាំបាច់របស់ភាគី ដើម្បីឲ្យមានតុល្យភាពជាមួយនឹងគោលការណ៍ប្រសិទ្ធភាពរបស់តុលាការ")។

[13] *សូមប្រៀបធៀប* **F13**, សំណើសុំការពិចារណាឡើងវិញលើចំនួនទំព័រកំណត់លើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង០០២/០១, ២ ធ្នូ ២០១៤, កថាខណ្ឌ ២។ **F13/2**, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប, ១១ ធ្នូ ២០១៤, កថាខណ្ឌ ១៥-១៦។ សំណុំរឿង០០១ - **F5/1**, សំណើរបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រដើម្បីដាក់សេចក្តីសន្និដ្ឋានបណ្តឹងសារទុក្ខរបស់ខ្លួន, ២៩ កញ្ញា ២០១០, កថាខណ្ឌ ២។ សំណុំរឿង ០០១ - **F5/2**, សេចក្តីសម្រេចលើសំណើពីររបស់សហព្រះរាជអាជ្ញា សុំបន្ថែមចំនួនទំព័រសម្រាប់ការដាក់សារណាបណ្តឹងសាទុក្ខរបស់ខ្លួន, ១៨ តុលា ២០១០, កថាខណ្ឌ ៦-៧។

*(២) ការដាក់បញ្ចូលគ្នានូវទឡ្ហីករណ៍ផ្សេងៗរបស់អ្នកប្តឹងសាទុក្ខដោយមានឯកសារយោង ពង្រីកយ៉ាងមានប្រសិទ្ធភាពដល់ប្រវែងនៃសារណាបណ្តឹងសាទុក្ខ*

8. បន្ទុករបស់សហព្រះរាជអាជ្ញាក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ គឺមានលក្ខណៈធំធេងជាងការគណនាធម្មតានៅលើចំនួនទំព័រ ដែលបានដាក់ដោយម្ចាស់បណ្តឹងសាទុក្ខ។ ហេតុផលចំបងមួយ គឺថាម្ចាស់ដើមបណ្តឹងសាទុក្ខទាំងពីរ បានបញ្ចូលអំណះអំណាងយ៉ាងវែងតាមរយៈការដាក់ឯកសារ ដោយប្រើឯកសារយោង។

9. ជាឧទាហរណ៍ ចំពោះបញ្ហាស្តីពីការភ្ជាប់ទំនងទំនងនៃលក្ខខណ្ឌតម្រូវផ្នែកច្បាប់រវាងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធ នួន ជា និយាយថា “តាមស្មារតីនៃការដាក់កម្រិតអំពីចំនួនទំព័រទៅលើការដាក់សារណានេះ និងអំណះអំណាងទូលំទូលាយ តម្រូវសម្រាប់ទឡ្ហីករណ៍ផ្សេងទៀតសម្រាប់បណ្តឹងសាទុក្ខ មេធាវីការពារក្តីពិចារណាថា ទម្រង់នៃកិច្ចដំណើរការនីតិវិធីមានប្រសិទ្ធភាពបំផុតគឺ ផ្តល់ជូនអង្គជំនុំជម្រះនូវសេចក្តីសន្និដ្ឋានសំខាន់ៗ ដែលមាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង”[14]។ នួន ជា ក៏បានដាក់បញ្ចូលតាមរយៈការយោងនូវអំណះអំណាងរបស់ អៀង សារី នៅលើប្រធានបទដូចគ្នានេះផងដែរ[15]។

10. អំណះអំណាងដែលបានដាក់បញ្ចូលទាំងនេះ មានប្រវែង២៧ទំព័រ[16]។ ដូចនេះ សហព្រះរាជអាជ្ញាមិនអាចសន្មតថា អង្គជំនុំជម្រះតុលាការកំពូលនឹងដោះស្រាយទឡ្ហីករណ៍ទាំងនោះ ហើយដូចនេះគ្មានជម្រើសអ្វីក្រៅពីធ្វើការឆ្លើយតបឡើយ។ សហព្រះរាជអាជ្ញាបានកាត់ចោលនូវពង្រាងនៃសេចក្តីសន្និដ្ឋានរបស់ខ្លួននៃប្រធានបទនេះ ពីចំនួន១៨ទំព័រ មកនៅត្រឹមតែ១៤ទំព័រ ប៉ុន្តែសហព្រះរាជអាជ្ញាមិនប្រាកដ ក្នុងការកាត់ចោលសេចក្តីសន្និដ្ឋានរបស់ខ្លួនបន្ថែមទៀតទេ និងនៅតែឆ្លើយតប

---

[14] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៤៦៨។

[15] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៤៦៨។

[16] **E95/5,** ចម្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យអង្គជំនុំជម្រះសាលាដំបូងដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ២២ កក្កដា ២០១១។ ការដាក់ឯកសារនេះមានប្រវែងសរុប៩ទំព័រ។ អំណះអំណាងសំខាន់ៗមានប្រវែងប្រហែល៦ទំព័រ។ **E95/81/1,** បណ្តឹងសាទុក្ខរបស់ អៀង សារី ប្រឆាំងនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើរបស់សហព្រះរាជអាជ្ញា សុំដកលក្ខខណ្ឌតម្រូវស្តីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ២៥ វិច្ឆិកា ២០១១, កថាខណ្ឌ២០ ដល់៦១, ដែលបានលើកយោងដោយ នួន ជា មានប្រវែងប្រហែល២១ ទំព័រ។

បានប្រកបដោយប្រសិទ្ធភាពទៅនឹងអំណះអំណាងបញ្ចូលគ្នារបស់ នួន ជា ដែលមានប្រវែងរហូតដល់២៧ទំព័រ។

11. នេះមិនមែនគ្រាន់តែជាប្រធានបទមួយដែល នួន ជា ពឹងផ្អែកនៅលើអំណះអំណាងបញ្ចូលគ្នាប៉ុណ្ណោះទេ។ គាត់បានបញ្ចូលអំណះអំណាងយោងលើឯកសារដែលទាក់ទងទៅនឹងភាពលម្អៀងរបស់អង្គជំនុំជម្រះ[17] ទំនាស់នៅក្នុង បកក ដូចដែលបានចោទប្រកាន់[18] ភាពខុសច្បាប់នៃការជម្លៀសទីក្រុងភ្នំពេញ[19] និងសហឧក្រិដ្ឋកម្មរួម[20] ផងដែរ។

12. ស្រដៀងគ្នានេះដែរ ខៀវ សំផន បញ្ចូលតាមរយៈអំណះអំណាងដែលមានឯកសារយោងចំនួន៤២ទំព័រ ទាក់ទងនឹងការបំបែកកិច្ចដំណើរការនីតិវិធី[21] ហើយក៏បានបញ្ចូលផងដែរនូវអំណះអំណាងដែលមានឯកសារយោងទាក់ទងនឹងសិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទ[22] សិទ្ធិនៃការជជែកដេញដោល[23] លក្ខខណ្ឌតម្រូវសម្រាប់ការភ្ជាប់ទំនងទំនាក់រវាងជម្លោះប្រដាប់អាវុធ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ[24] និងស្ថានការណ៍នៅភ្នំពេញមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[25]។ នេះជាការរៀបរាប់មិនមានការពិចារណាល្អិតល្អន់។

---

[17] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៥២, ៥៤។

[18] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ២៥៧ & កំណត់សម្គាល់ជើងទំព័រ ៦៥៨។

[19] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៤៣៤ & កំណត់សម្គាល់ជើងទំព័រ ១១៥៥។

[20] បណ្តឹងសាទុក្ខរបស់ នួន ជា, កថាខណ្ឌ ៤៨៧ & កំណត់សម្គាល់ជើងទំព័រ ១២៩៧។

[21] បណ្តឹងសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ១២, កំណត់សម្គាល់ជើងទំព័រ១៦ *ដាក់បញ្ចូល* **E275/2/1/1** សំណើបន្ទាន់សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម, ០១ សីហា ២០១៣, កថាខណ្ឌ១៩-៥១ (ទំព័រ៦-១៦)។ **E295/6/4** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល, ២៦ កញ្ញា ២០១៣, កថាខណ្ឌ១-៩ (ទំព័រ៥-៧)។ ប្រតិចារឹក, ២៥ តុលា ២០១៣, ទំព័រ៣-៣០។

[22] បណ្តឹងសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ១៦-១៧, កំណត់សម្គាល់ជើងទំព័រ៣៤-៣៥ *ដាក់បញ្ចូល* **E275/2/1/1** សំណើបន្ទាន់សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម, ០១ សីហា ២០១៣, កថាខណ្ឌ៥៤-៦៨ (ទំព័រ១៧-២០)។ ឯកសារ **E275/2/1/3** សេចក្តីបន្ថែមទៅលើសំណើសុំ (ទំព័រ១)។

[23] បណ្តឹងសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ២៣, កំណត់សម្គាល់ជើងទំព័រ៥០ *ដាក់បញ្ចូល* **E275/2/1/1** សំណើបន្ទាន់សុំឱ្យបញ្ឈប់កិច្ចដំណើរការនីតិវិធីភ្លាម, ០១.សីហា.២០១៣, កថាខណ្ឌ៧៨-៨១ (ទំព័រ២៣-២៧)។ ឯកសារ **E275/2/1/3** សេចក្តីបន្ថែមទៅលើសំណើសុំ (ទំព័រ១)។

[24] បណ្តឹងសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ៥៣, កំណត់សម្គាល់ជើងទំព័រ៥១៥ *ដាក់បញ្ចូល* **E95/3** ចម្លើយតបរបស់ ខៀវ សំផន, ២២.កក្កដា.២០១១, កថាខណ្ឌ២១-២២ (ទំព័រ៦-៨)។ **E95/8/1/1** បណ្តឹងឧទ្ធរណ៍របស់ អៀង សារី, ២៥.វិច្ឆិកា.២០១១, កថាខណ្ឌ២៦-៥៦ (ទំព័រ១០-២៦)។

13. ការដាក់បញ្ចូលទាំងនេះ បង្កើតបានជាការបន្ថែមសំខាន់មួយ ដល់សារណាបណ្តឹងសាទុក្ខដែលមាន ៤៨០ទំព័រ។ នេះជាផលប្រយោជន៍នៃយុត្តិធម៌ ដែលសហព្រះរាជអាជ្ញាគួរត្រូវបានផ្តល់ចំនួនទំព័របន្ថែម ដើម្បីឆ្លើយតបទៅនឹងអំណះអំណាងដែលមានឯកសារយោងដែលបន្ថយចំនួនទំព័រកំណត់ដែលបានកម្រិតលើសារណាបណ្តឹងសាទុក្ខ។

### *(៣) ដោយមកពីអំណះអំណាងរបស់ ខៀវ សំផន មានន័យមិនច្បាស់ និងស្រពិចស្រពិល តម្រូវឱ្យប្រើច្រើនទំព័រជាងតម្រូវឱ្យពង្រាងអំណះអំណាង*

14. ដូចដែលសហព្រះរាជអាជ្ញាបានកត់សម្គាល់ពីមុនដូច្នោះដែរ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន មិនមានភាពច្បាស់លាស់ ទាក់ទងទៅនឹងទឡ្ហីករណ៍ពិតប្រាកដនៃបណ្តឹងសាទុក្ខនេះ ហើយថាតើអំណះអំណាងក្នុងសារណានេះ គាំទ្រដល់ទឡ្ហីករណ៍នៃបណ្តឹងសាទុក្ខ[26]។ មិនដូចគ្នាទៅនឹងរបៀបតាមប្រពៃណីនៃការរៀបចំសារណាបណ្តឹងសាទុក្ខ ដែលអំណះអំណាងជាក់លាក់ ត្រូវបានរៀបរាប់នៅក្នុងទឡ្ហីករណ៍ជាក់លាក់នៃបណ្តឹងសាទុក្ខនេះ សារណានេះមិនបានបញ្ជាក់អំពីថាតើទឡ្ហីករណ៍ណាមួយនៃបណ្តឹងសាទុក្ខ ត្រូវគ្របដណ្តប់ទៅលើផ្នែកណា ឬបញ្ជាក់អ្វីដែលជាកំហុសពិតប្រាកដខាងអង្គច្បាប់ និងខាងអង្គហេតុដែលបានចោទប្រកាន់។

15. កំហុសធំបំផុតនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន គឺការខកខានមិនបានបញ្ជាញឱ្យបានច្បាស់ៗ ថាតើអ្វីដែលត្រូវបានចាត់ទុកថាជាកំហុសនោះ។ ខៀវ សំផន បានចោទប្រកាន់ថាកំហុសមួយមានអត្ថិភាពដោយទាក់ទងនឹងប្រធានបទ ឬបញ្ហាជាក់លាក់មួយ ក៏ប៉ុន្តែជាញឹកញាប់គាត់ខកខានមិនបានបញ្ជាក់ថាតើ (i) គាត់ចោទប្រកាន់ពីកំហុសខាងអង្គច្បាប់ ឬខាងអង្គហេតុ, (ii) បើជាកំហុសខាងអង្គច្បាប់ តើបទដ្ឋានច្បាប់អ្វីជាក់លាក់ ដែលត្រូវ បានកំណត់ថាមិនត្រឹមត្រូវ ហើយបទដ្ឋានត្រឹមត្រូវនោះគឺអ្វី, (iii) បើជាកំហុសខាងអង្គហេតុ តើអង្គហេតុជាក់លាក់ណាមួយ

---

[25] បណ្តឹងសាទុក្ខរបស់ ខៀវ សំផន, កថាខណ្ឌ២២៤, កំណត់សម្គាល់ជើងទំព័រ៥១៥ *ដាក់បញ្ចូល* **E295/6/4** សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល, ២៦ កញ្ញា ២០១៣, កថាខណ្ឌ៣៤-៥៣ (ទំព័រ១៦-២៧)។ ប្រតិចារឹក, ២៥ តុលា ២០១៣, ទំព័រ ៦៦-៨៤។

[26] *សូមអាន* **F18** សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យដោះស្រាយចំពោះវិការៈនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន, ៦ មករា ២០១៥។ **F18/2** ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់មេធាវីការពារក្តីទៅនឹងសំណើសុំឱ្យដោះស្រាយចំពោះវិការៈនៅក្នុងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន, ១៥ មករា ២០១៥។

ដែលត្រូវបានរកឃើញថាមិនត្រឹមត្រូវ ហើយតើការរកឃើញអ្វីដែលត្រឹមត្រូវនោះ, និង (iv) នៅក្នុងករណីណាក៏ដោយ តើកំហុសដែលបានចោទប្រកាន់នោះ ប៉ះពាល់ទៅលើសាលក្រមយ៉ាងដូចម្តេចដែរ។ ទោះបីជាអង្គជំនុំជម្រះនេះ ធ្លាប់បានសម្រេចថាអំណះអំណាងណាមួយក៏ដោយ ដែលមិនមានសម្អាងហេតុ នឹងត្រូវចាត់ទុកថាបានបោះបង់ចោល[27] នៅត្រង់ចំណុចនេះ សហព្រះរាជអាជ្ញាមិនអាចដឹងបានទេ ថាតើអំណះអំណាងណាមួយដែលអង្គជំនុំជម្រះនេះយល់ឃើញថាមាន ឬមិនមានសម្វាងហេតុនោះ ហេតុដូច្នោះហើយមិនមានការប្រុងប្រយ័ត្នច្រើន ត្រូវតែឆ្លើយតបទៅនឹងអំណះអំណាងទាំងអស់ឲ្យបានពេញលេញ។ ជាលទ្ធផល សហព្រះរាជអាជ្ញាតែងតែត្រូវបានតម្រូវឲ្យរៀបផែនការ និងព្រាងចម្លើយតបជាបី ឬបួនផ្នែក ទៅនឹងអំណះអំណាងមួយដែលមានតែបី ឬបួនបន្ទាត់។ ក្នុងការឆ្លើយតបទៅនឹងអំណះអំណាងទាំងនេះដែលជាញឹកញាប់មានន័យមិនច្បាស់ និងស្រពិចស្រពិល ចាំបាច់តម្រូវឲ្យមានច្រើនទំព័រ និងចំណាយពេលវេលាច្រើន ដើម្បីធ្វើការឆ្លើយតប។

16. ជាឧទាហរណ៍ នៅត្រង់កថាខណ្ឌ ៤៣៨ នៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន បានអះអាងថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសដោយអង្គជំនុំជម្រះនេះបានកត់សម្គាល់ថា "...មិនមានភស្តុតាងបង្ហាញថា លោក ខៀវ សំផន បានដឹងពីចរិកលក្ខណៈនៃឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តនៅទួលពោធិ៍ជ្រៃ..." ហើយថាការរកឃើញនេះបានរារាំងដល់សេចក្តីសន្និដ្ឋានដែលហួសពីវិមតិសង្ស័យដែលថា ខៀវ សំផន មានចេតនាក្នុងការធ្វើឲ្យឧក្រិដ្ឋកម្មនានា ត្រូវបានប្រព្រឹត្ត។ ការណ៍នេះគឺជាការសរុបរួមនៃអំណះអំណាង ដោយពុំមានការពន្យល់ ឬការផ្តល់យុត្តិសាស្ត្រគាំទ្របន្ថែមឡើយ។

17. ដូច្នេះ មិនមានភាពច្បាស់លាស់ទេចំពោះទឡ្ហីករណ៍ដែលថាអ្វីជាកំហុសរបស់ ខៀវ សំផន កំពុងចោទប្រកាន់។ អាចថាគាត់កំពុងលើកឡើងចោទប្រកាន់ពីកំហុសអង្គច្បាប់ ដោយបាន អះអាងថាការដឹងឮជាក់លាក់ពីឧក្រិដ្ឋកម្ម តម្រូវឲ្យមានការបង្ហាញញពីចេតនា។ ដោយសម្អាង លើលទ្ធភាពក្នុងការបកស្រាយ សហព្រះរាជអាជ្ញាត្រូវតែពិនិត្យមើលពីលក្ខខណ្ឌតម្រូវនានានៃ *បំណងឧក្រិដ្ឋ* សម្រាប់ទម្រង់<u>ទាំងអស់</u>នៃការទទួលខុសត្រូវដែលអាចអនុវត្តបានជាសក្តានុពល[28]។ ម្យ៉ាងវិញ

[27] **F18/3**, សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន, ១៦ មករា ២០១៥, ទំព័រ ៤។

[28] ការវិភាគនេះត្រូវតែបានដំណើរការឡើងតាមទម្រង់រៀងៗខ្លួន។ ឧទាហរណ៍ ការជួយ និងការជំរុញ តម្រូវឲ្យជនជាប់ចោទមានការដឹងឮពីធាតុផ្សំនានានៃឧក្រិដ្ឋកម្ម។

ទៀត គាត់អាចចោទប្រកាន់ពីកំហុសខាងអង្គហេតុ ឬក៏លើកស្នើឡើងថា ការរកឃើញមួយចំនួនរបស់អង្គជំនុំជម្រះសាលាដំបូង គឺមានលក្ខណៈពិសេសទៅវិញទៅមក។ ដូច្នេះ ការអះអាងមួយបែបដូចគ្នានេះ តម្រូវឲ្យមានចម្លើយតបចំនួនពីរកថាខណ្ឌ។ សារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ពោរពេញទៅដោយការអះអាងបែបអញ្ជឹង គឺមានលក្ខណៈ៖ ខ្លី ស្រពិចស្រពិល ដែលតម្រូវឲ្យមានការសន្និដ្ឋានគ្រប់គ្រាន់សម្រាប់ការឆ្លើយតបមួយមានលក្ខណៈទូលំទូលាយ ទើបសហព្រះរាជអាជ្ញាអាចជួយដល់អង្គជំនុំជម្រះ ក្នុងបណ្តឹងសាទុក្ខនេះបាន។

18. កង្វះខាតនៃអំណះអំណាងនៅក្នុងបណ្តឹងសាទុក្ខដែលបានកែតម្រូវរបស់ ខៀវ សំផន គឺត្រូវបានដាក់ចូលគ្នាដោយវិធីសាស្ត្រ "និក្ខេបបទ" ចំពោះការចោទប្រកាន់នានាដែលគាត់បានលើកឡើងទាក់ទងនឹងការទទួលខុសត្រូវខាងព្រហ្មទណ្ឌរបស់គាត់។ ការណ៍នេះចាប់ផ្តើមពីសេចក្តីជូនដំណឹងរបស់គាត់ ដែលនៅក្នុងនោះ គាត់បានចោទប្រកាន់ពីកំហុសផ្សេងៗ ទាក់ទងនឹងទម្រង់នានានៃការទទួលខុសត្រូវ។ ដូច្នេះ ជាឧទាហរណ៍ ខៀវ សំផន បានចោទប្រកាន់អង្គជំនុំជម្រះសាលាដំបូងថាមានកំហុសខាងអង្គហេតុ និងអង្គច្បាប់ នៅពេលមានវត្តមាន របស់គាត់នៅក្នុងកិច្ចប្រជុំនានានៅទូទាំងរយៈពេលធ្វើបដិវត្ត និងក្នុងរយៈពេលនៃកម្ពុជាប្រជាធិបតេយ្យ[29]។ គាត់សុំឲ្យអង្គជំនុំជម្រះតុលាការកំពូលអនុវត្តជាចាំបាច់នូវអំណះអំណាងដដែលនេះ ឲ្យបានស្មើៗគ្នាទៅនឹងសហឧក្រិដ្ឋកម្មរួម, ការធ្វើផែនការ និងការញុះញង់ ដោយពុំមានការបរិយាយបន្ថែមទៀតឡើយ។

19. ហេតុដូច្នេះ ដើម្បីឆ្លើយតបឲ្យបានត្រឹមត្រូវ សហព្រះរាជអាជ្ញាត្រូវតែ៖ (១) រៀបចំឡើងវិញនូវការចោទប្រកាន់បែបនិក្ខេបបទ អំពី "ទឡ្ហីករណ៍នានា" ដែល ខៀវ សំផន បានដាក់នៅក្នុងសេចក្តីជូនដំណឹងរបស់គាត់ គឺថាស្របទៅតាមទម្រង់នានានៃការទទួលខុសត្រូវ។ ដូច្នេះ ជាឧទាហរណ៍ ទាក់ទងនឹងកិច្ចប្រជុំនានាដែល ខៀវ សំផន បានចោទប្រកាន់ម្តងរួចមកហើយ សហព្រះរាជអាជ្ញាចាំបាច់ត្រូវធ្វើការឆ្លើយតបចំនួនបីដង - គឺម្តងអំពីទម្រង់នៃការទទួលខុសត្រូវនីមួយៗ ដែលបានដកស្រង់ (២) រៀបរាប់អំពីច្បាប់ដែលបានតម្រូវ ចំពោះការចោទប្រកាន់ទាំងឡាយដែល ខៀវ សំផន បានលុបចោលទាំងអស់ និង (៣) រៀបរាប់អំពីការវិភាគ និងការយល់ឃើញទាំងឡាយដែលមានលក្ខណៈខុសៗគ្នារបស់អង្គជំនុំជម្រះសាលាដំបូង អំពីភស្តុតាងនៅពេលអនុវត្តច្បាប់ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវនីមួយៗ ដែលការចោទប្រកាន់ទាំងអស់របស់ ខៀវ សំផន ខកខានមិនបានយកមកពិចារណា។ ដូច្នេះ នៅពេល ខៀវ សំផន អាចចោទប្រកាន់នៅក្នុងកថាខណ្ឌ

[29] បណ្តឹងសាទុក្ខដែលបានកែតម្រូវរបស់ ខៀវ សំផន ត្រង់កថាខណ្ឌ ២៩៦-២៩៨, ៤៤៣ និង៦០២-៦០៥។

មួយ ឬពីរ ឬជាងនេះទៅទៀត មួយ ឬ ពីរបន្ទាត់ គឺអាចនឹងតម្រូវឲ្យមានពីប្រាំមួយ ទៅប្រាំបួនកថាខណ្ឌ ដើម្បីរៀបចំចម្លើយតបមួយ ឲ្យបានទាក់ទងគ្នា និងត្រឹមត្រូវ - ពីរ ទៅបីកថាខណ្ឌសម្រាប់ទម្រង់នៃការទទួលខុសត្រូវនីមួយៗ។

20. ទីបំផុតសម្រាប់អង្គជំនុំជម្រះធ្វើការសម្រេចហើយ ថាតើអង្គជំនុំជម្រះត្រូវការជំនួយប៉ុនណា នៅក្នុងបណ្ដឹងសាទុក្ខនេះ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាជូនសេចក្ដីសន្និដ្ឋានថា តាមរយៈការអនុញ្ញាតបន្ថែមទំព័រឲ្យដល់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតបទៅនឹងអំណះអំណាងដែលមានន័យមិនច្បាស់ និងស្រពិចស្រពិលទាំងនេះ ដែលនាំឲ្យមានការបកស្រាយជាច្រើននេះ នឹងធ្វើឲ្យអង្គជំនុំជម្រះបានជ្រួតជ្រាបបានល្អប្រសើរ ដើម្បីធ្វើការសម្រេចលើទឡ្ហីករណ៍ជាច្រើនដែលបានលើកឡើងនេះ។

### *ខ. ការបន្ថែមពេលវេលាកំណត់*

### *(៤) អង្គជំនុំជម្រះនឹងទទួលបានជំនួយយ៉ាងល្អប្រសើរ បើសិនភាគីមានឱកាសស្មើៗគ្នា ដើម្បីធ្វើអំណះអំណាងរបស់ខ្លួន*

21. ពេលវេលាស្មើគ្នាសម្រាប់ការលើកសម្អាងដែលគេបានទទួលយក មិនមែនមានន័យថាត្រូវបានផ្ដល់ជូនប្រកបដោយយន្តការ ដោយគ្មានយុត្តិកម្មតាមរយៈកាលៈទេសៈសត្យានុម័តនោះទេ[30]។ ប៉ុន្តែពេលវេលាដែលបានផ្ដល់ឲ្យភាគីមួយ ដើម្បីរៀបចំសេចក្ដីសន្និដ្ឋានរបស់ខ្លួន គឺមានការពាក់ព័ន្ធទៅនឹងពេលវេលាតម្រូវសម្រាប់ភាគី ដើម្បីរៀបចំចម្លើយតបមួយឲ្យមានប្រសិទ្ធភាព។ ម្ចាស់បណ្ដឹងសាទុក្ខមានពេលដល់ទៅ២០សប្ដាហ៍ ដើម្បីដាក់ចម្លើយតបរបស់ខ្លួនទៅនឹងសាលក្រមដែលបានចេញទាំងបីភាសា ដោយហេតុថាដូចបានឃើញនៅពេលនេះ សហព្រះរាជអាជ្ញានឹងមានពេលតែ១៦សប្ដាហ៍ ដើម្បីធ្វើការឆ្លើយតបបន្ទាប់ពីទទួលបានសារណាបណ្ដឹងសាទុក្ខតែមួយភាសា។ ដើមបណ្ដឹងសាទុក្ខមានពេលច្រើនជាង២៥ភាគរយ សម្រាប់រៀបចំបណ្ដឹងសាទុក្ខរបស់ខ្លួន លើសសហព្រះរាជអាជ្ញាដែលត្រូវឆ្លើយតបទៅវិញ គឺមានសារៈសំខាន់ចំពោះសហព្រះរាជអាជ្ញា ជា

---

[30] **F9**, សេចក្ដីសម្រេចលើសំណើសុំពន្យាររយៈពេល និងបន្ថែមចំនួនទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ និងសារណាតប, ៣១ តុលា ២០១៤, កថាខណ្ឌ១៤។

ពិសេសនៅពេលពិចារណាពីកត្តាបន្ថែម ដែលប៉ះពាល់ដល់ថិរវេលាពាក់ព័ន្ធដូចបានកំណត់ខាងក្រោម[31]។

*(៥) ពហិការរបស់ដើមបណ្ដឹងសាទុក្ខ ក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៃសំណុំរឿង០០២/០២ បានធ្វើឲ្យពួកគេបានចំណេញច្រើនតាមរយៈយុទ្ធវិធីមិនយុត្តិធម៌ ដែលអង្គជំនុំជម្រះគប្បីពិចារណា*

22. ជាការបន្ថែម ពេលវេលាបន្ថែម២៥ភាគរយ ដែលដើមបណ្ដឹងសាទុក្ខមានសម្រាប់ត្រៀមលក្ខណៈចំពោះសារណាបណ្ដឹងសាទុក្ខរបស់ពួកគាត់ គឺមានផលចំណេញច្រើនចំពោះពេលវេលាដែលពួកគេបានទទួលពីការធ្វើពហិការមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការកាលពីខែវិច្ឆិកា និងធ្នូ ឆ្នាំ២០១៤។ តាមរយៈការមិនចូលរួម និងប្រកាន់គោលជំហរមិនចូលរួមក្នុងសវនាការនៅក្នុងរយៈពេលនេះ ដែលបានបង្ខំឲ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកដំណើរការនីតិវិធីនានា ដោយអនុញ្ញាតឲ្យម្ចាស់បណ្ដឹងសាទុក្ខមានពេលធ្វើការងាររបស់ខ្លួន ទៅលើតែសារណាបណ្ដឹងសាទុក្ខតែមួយគត់របស់ពួកគេប៉ុណ្ណោះ។

23. ខៀវ សំផន និងក្រុមមេធាវីការពារក្ដីរបស់គាត់ បានបញ្ជាក់យ៉ាងច្បាស់ថា គោលបំណងនៃការធ្វើពហិការ គឺដើម្បីទទួលបានពេលវេលាឲ្យបានច្រើន និងមានប្រសិទ្ធភាពសម្រាប់ធ្វើសេចក្ដីព្រាងសារណាបណ្ដឹងសាទុក្ខរបស់ពួកគេ។ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៤ ខៀវ សំផន បានថ្លែងជូនអង្គជំនុំជម្រះសាលាដំបូងថា៖ “មេធាវីការពារក្ដីរបស់ខ្ញុំបានប្រាប់ខ្ញុំថា ពួកគេមិនអាច ម្ខាងត្រូវចូលរួមក្នុងដំណើរការនីតិវិធី និងម្ខាងទៀត ត្រូវរៀបចំបណ្ដឹងសាទុក្ខឲ្យបានគ្រប់ជ្រុងជ្រោយនៅចំពោះមុខអង្គជំនុំជម្រះឡើយ[...]។ ខ្ញុំត្រូវតែបង្ខំចិត្តប្រាប់មេធាវីការពារក្ដីខ្ញុំឲ្យប្រឹងប្រែងឲ្យបានខ្លាំងក្លាក្នុងការរៀបចំបណ្ដឹងសាទុក្ខ[...]។ ទាក់ទងចំណុចនេះ មេធាវីមិនអាចចូលរួមក្នុងដំណើរការនីតិវិធីនៃសំណុំរឿង០០២/០២ ដែលកំពុងតែធ្វើពេលនេះបានឡើយ”[32]។ ភ្លាមៗបន្ទាប់ពីចំណាប់អារម្មណ៍របស់ ខៀវ សំផន មេធាវីរបស់គាត់ និងមេធាវីការពារក្ដី នួន ជា ក៏បានដើរចេញ

[31] ការពិតដែលម្ចាស់បណ្ដឹងសាទុក្ខបានចំណាយពេលមួយផ្នែកនៃរយៈពេល២០សប្ដាហ៍ រៀបចំ និងធ្វើសេចក្ដីព្រាងសេចក្ដីជូនដំណឹងបណ្ដឹងសាទុក្ខរបស់ខ្លួននោះ មិនបានកែប្រែការវិភាគនេះទេ។ វាមិនសមស្របទេដែលគេគិតថា ដំណើរការសរសេរបណ្ដឹងសាទុក្ខត្រូវចាប់ផ្ដើមនៅពេលណាការជូនដំណឹងបណ្ដឹងសាទុក្ខត្រូវបានដាក់នោះ។ តាមពិត ដំណើរការធ្វើសេចក្ដីព្រាងអំណះអំណាង និងការរៀបចំអំណះអំណាងទាំងនោះទៅជាទម្រង់ឯកសារនៃបណ្ដឹងសាទុក្ខ គឺជាផ្នែកដ៏សំខាន់ទាំងមូលនៃដំណើរការបណ្ដឹងសាទុក្ខ។

[32] **E1/242.1**, ប្រតិចារឹក, ១៧ តុលា ២០១៤, ទំព័រ ៧៦-៧៧។

ពីបន្ទប់សវនាការដោយគ្មានការអនុញ្ញាតពីអង្គជំនុំជម្រះសាលាដំបូង[33] និងតាមរយៈនេះហើយបន្តទទួលបានអត្ថប្រយោជន៍ក្នុងការផ្តោតអារម្មណ៍ជារួមទៅលើតែសារណាបណ្តឹងសាទុក្ខតែមួយមុខក្នុងអំឡុងពេលពីរខែកន្លះនោះ[34]។

24. នៅពេលមិនបន្ថយចំពោះការដើរចេញនោះ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាអន្តរជាតិយល់ពីការលំបាករបស់ដើមបណ្តឹងសាទុក្ខ ចំពោះការចូលរួមប្រកបដោយប្រសិទ្ធភាពនៅក្នុងដំណើរការពីរក្នុងពេលតែមួយ ហើយ "នៅពេលមេធាវីការពារក្តីនិយាយអំពីការលំបាកនៃការធ្វើការងារទាំងបណ្តឹងសាទុក្ខផង និងសវនាការផងក្នុងពេលតែមួយ ខ្ញុំអាណិតពួកគាត់ដោយហេតុថា យើងក៏ស្ថិតក្នុងស្ថានភាពដូចពួកគាត់ដែរ ហើយយើងគ្រាន់តែមានផែនការធ្វើការងារទាំងពីរ"[35]។

25. ផ្ទុយពីដើមបណ្តឹងសាទុក្ខ សហព្រះរាជអាជ្ញាមិនបានស្វែងរកការពន្យារពេលដំណើរការនីតិវិធីក្នុងសំណុំរឿង០០២/០២ នៅពេលកំពុងធ្វើការលើសារណាចម្លើយតប។ ជាងនេះទៀត សហព្រះរាជអាជ្ញាបានធ្វើអ្វីដែលអាចធ្វើទៅបានដើម្បីធានាឲ្យសវនាការបានចាប់ផ្តើម ដូចដែរអង្គជំនុំជម្រះបានចេញបង្គាប់ថា "ឆាប់រហ័សដែលអាចធ្វើទៅបាន"[36] និងថាឲ្យដំណើរការឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ រួមជាមួយនឹងសវនាការសំណុំរឿង០០២/០២ និងចម្លើយតបបណ្តឹងសាទុក្ខ

---

[33] **E1/242.1**, ប្រតិចារឹក, ១៧ តុលា ២០១៤, ទំព័រ ៩១។

[34] សូម្បីតែនៅពាក់កណ្តាលនៃពហិការរបស់ដើមបណ្តឹងសាទុក្ខនៃសវនាការក្នុងសំណុំរឿង០០២/០១ក្តី ក៏អង្គជំនុំជម្រះនេះនៅតែយោគយល់ចំពោះអំណះអំណាងរបស់ដើមបណ្តឹងសាទុក្ខថា ការធ្វើសេចក្តីព្រាងសារណាបណ្តឹងសាទុក្ខរបស់ពួកគេ គឺជាការងារពេញម៉ោង។ នៅថ្ងៃទី១ និងទី២ ខែធ្នូ ឆ្នាំ២០១៤ ម្ចាស់ដើមបណ្តឹងសាទុក្ខបានស្នើសុំការពន្យារពេលសម្រាប់ដាក់ចម្លើយតបរបស់ខ្លួនទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ដោយសារតែការងាររបស់ខ្លួនលើសារណាបណ្តឹងសាទុក្ខរបស់ពួកគេ។ អង្គជំនុំជម្រះបានរកឃើញថា វាជាការសមស្របដោយបានយល់ព្រមតាមសំណើនេះ ដោយសារការងារឆ្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា "នឹងតម្រូវឲ្យ នួន ជា និង ខៀវ សំផន ត្រូវបង្វែរការផ្តោតអារម្មណ៍របស់ពួកគាត់ពីសារណាបណ្តឹងសាទុក្ខរបស់ពួកគាត់ ដោយត្រូវផុតនៅក្នុងចុងខែនេះ"។ **F13/2**, សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប, ១១ ធ្នូ ២០១៤, កថាខណ្ឌ១, ៦, ១១-១៤។ ការទទួលយកថា ដើមបណ្តឹងសាទុក្ខមិនអាចធ្វើការងារប្រជេញគ្នាក្នុងពេលតែមួយនៅលើសារណាបណ្តឹងសាទុក្ខ និងចម្លើយតបទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ទោះបីអវត្តមាននៃការទទួលខុសត្រូវក្នុងសវនាការក៏ដោយ ខណៈមានការច្រានចោលជាប្រចាំមិនព្រមគិតគូរអំពីការទទួលខុសត្រូវរបស់សហព្រះរាជអាជ្ញាក្នុងសវនាការ ក្នុងគោលបំណងដើម្បីកំណត់កាលបរិច្ឆេទចុងក្រោយសម្រាប់ចម្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខ គឺជាការបង្ហាញនៃភាពមិនស្មើគ្នាគួរឲ្យភ្ញាក់ផ្អើល។

[35] **E1/242.1**, ប្រតិចារឹក, ១៧ តុលា ២០១៤, ទំព័រ ៨៧។

[36] **E284/4/7**, សេចក្តីសម្រេចស្តីពីបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទី២របស់អង្គជំនុំជម្រះសាលាដំបូងស្តីពីសម្អាងហេតុសង្ខេបជាច្រើននៃសំណុំរឿង០០២ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣ កថាខណ្ឌ១១។

សហព្រះរាជអាជ្ញាបានចូលរួមសកម្មក្នុងការស៊ើបអង្កេតក្នុងសំណុំរឿង០០៣ និង០០៤។ ជាងនេះទៀត សហព្រះរាជអាជ្ញាបានប្រើប្រាស់ពេលវេលាដូចគ្នា ក្រៅពីការងារចម្បងពិនិត្យឡើងវិញនូវកំណត់ហេតុស្តាប់ចម្លើយចំនួន៨០០នៃកិច្ចស៊ើបសួរ និងធ្វើសំណើសមស្របសុំដាក់បង្ហាញព័ត៌មានពាក់ព័ន្ធ។ ថ្មីៗនេះ អង្គជំនុំជម្រះបានបញ្ជាក់ពីសារៈសំខាន់នៃការងារ និងបង្គាប់ឲ្យសហព្រះរាជអាជ្ញាធ្វើការប្រឹងប្រែងបន្ថែមទៀតក្នុងបញ្ហានេះ[37]។

26. គ្មានអ្វីសង្ស័យទេថា ដើមបណ្ដឹងសាទុក្ខបានទាញយកផលប្រយោជន៍តាមយុទ្ធសាស្ត្រពិតប្រាកដមួយពីសកម្មភាពទាំងនេះ។ ពហិការរបស់ពួកគេបានធ្វើឲ្យពួកគេមិនមានការរំខានចំពោះការផ្ដោតអារម្មណ៍របស់ពួកគេជាច្រើនខែ ក្នុងការធ្វើសេចក្ដីព្រាងបណ្ដឹងសាទុក្ខរបស់ខ្លួន។ ផ្ទុយមកវិញ សហព្រះរាជអាជ្ញាត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនយ៉ាងច្រើន ទាំងនៅលើបណ្ដឹងសាទុក្ខ សវនាការ និងដំណើរការស៊ើបសួរដែលកើតឡើងក្នុងពេលដំណាលគ្នា។ ដើម្បីធានាបានភាពយុត្តិធម៌នៅក្នុងដំណើរការនេះ សហព្រះរាអាជ្ញាសូមស្នើអង្គជំនុំជម្រះពិចារណាពីទម្ងន់ការងារធ្ងន់ជាងដែលមានចំពោះខ្លួនក្នុងរយៈពេលនេះ និងពហិការរបស់ដើមបណ្ដឹងសាទុក្ខក្នុងការមិនចូលរួមក្នុងកិច្ចដំណើរការនីតិវិធីសវនាការដែលរួមបង្កើតពេលវេលាបានច្រើន សម្រាប់ធ្វើសេចក្ដីព្រាងបណ្ដឹងសាទុក្ខរបស់ដើមបណ្ដឹងសាទុក្ខ ជាងសហព្រះរាជអាជ្ញា។ ការខកខានមិនបានថ្លឹងថ្លែងពីចំណុចដូច្នេះនឹងបង្ហាញឲ្យឃើញកាន់តែច្បាស់ និងធ្វើឲ្យមានប្រយោជន៍ជាអចិន្ត្រៃយ៍ដល់ដើមបណ្ដឹងសាទុក្ខទទួលបានពីការធ្វើពហិការមិនចូលរួមសវនាការ។ អង្គជំនុំជម្រះនេះមិនគួរលើកទឹកចិត្តចំពោះឥរិយាបថរបស់ដើមបណ្ដឹងសាទុក្ខតាមរបៀបនេះទេ នៅពេលធ្វើឲ្យខូចផលប្រយោជន៍របស់សហព្រះរាជអាជ្ញា។

### *(៦) ការកំណត់លក្ខខណ្ឌតម្រូវឲ្យដាក់ចម្លើយតបរួមក្នុងរយៈពេល៣០ថ្ងៃ បន្ទាប់ពីសារណានៃបណ្ដឹងសាទុក្ខជាភាសាខ្មែរ មិនផ្ដល់ពេលវេលាគ្រប់គ្រាន់សម្រាប់បុគ្គលិកជាតិ និងអន្តរជាតិធ្វើការរួមគ្នាដូចអង្គជំនុំជម្រះបានសម្រេចជាការតម្រូវ*

27. ដើម្បីសម្រេចលើសំណើសុំបន្ថែមពេលវេលាកំណត់ អង្គជំនុំជម្រះគួរពិចារណាផងដែរលើភាពអាចរកបាននៃសារណាបណ្ដឹងសាទុក្ខជាភាសាខ្មែរ។ ដូចអង្គជំនុំជម្រះបានថ្លែងយ៉ាងត្រឹមត្រូវថា

[37] **F2/4/2**,សេចក្ដីសម្រេចជាផ្នែកនៃសំណើសុំលើកទី៣របស់ នួន ជា ឲ្យទទួលយក និងពិចារណាលើភស្តុតាងបន្ថែម ក្នុងនីតិវិធីលើបណ្ដឹងសាទុក្ខនៃសំណុំរឿង០០២/០១ ថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៥ កថាខណ្ឌ១៧-២០។

"សារៈសំខាន់នៃការដាក់ឯកសារជាភាសាខ្មែរ មិនអាចត្រូវគេមើលរំលងនោះឡើយ[.] […]។ ដូច្នេះ ឯកសារជាភាសាខ្មែរនៃការដាក់ឯកសារណាមួយនៅចំពោះមុខ អ.វ.ត.ក គឺជាផ្នែកដ៏សំខាន់មិនអាចខ្វះបាននៃកិច្ចដំណើរការនីតិវិធីនៅតុលាការនេះ ដោយហេតុថា សមាសភាពជាតិ និងអន្តរជាតិនិមួយៗត្រូវធ្វើការងារជាមួយគ្នាដើម្បីទទួលបានលទ្ធផល"[38]។

28. ដូចបានធ្វើការកត់សម្គាល់ពីខាងលើ ដើមបណ្តឹងសាទុក្ខមានលទ្ធភាពចូលពិនិត្យមើលសាលក្រមជាភាសាខ្មែរ អង់គ្លេស និងបារាំង អស់រយៈពេល២០សប្តាហ៍ នៅមុនថ្ងៃតម្រូវឲ្យដាក់សារណាបណ្តឹងសាទុក្ខរបស់ពួកគេ។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញានឹងមានលទ្ធភាពចូលពិនិត្យមើលសារណានៃបណ្តឹងសាទុក្ខជាភាសាខ្មែរតែ៣០ថ្ងៃមុនពេលត្រូវដាក់ចម្លើយតបរួម។ កាលបរិច្ឆេទកំណត់នេះពិតជាមិនអនុញ្ញាតឲ្យ "សមាសភាពជាតិ និងអន្តរជាតិ" នៃការិយាល័យសហព្រះរាជអាជ្ញា "ធ្វើការរួមគ្នាដើម្បីទទួលបានលទ្ធផល" ដូចអង្គជំនុំជម្រះបានសម្រេចជាការតម្រូវ។

29. នៅពេលមកដល់ចំណុចសំខាន់នេះក្នុងកិច្ចដំណើរការនីតិវិធីនានា សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិចាំបាច់ និងត្រូវឲ្យគេមើលឃើញផងដែរថា គឺជាដៃគូស្មើភាពគ្នា នៅក្នុងការចោទប្រកាន់នៃសំណុំរឿង០០២/០១។ សកម្មភាពណាដែលទំនងជាមានហានិភ័យដែលនឹងប្រឈម ឬហាក់ដូចជាប្រឈមដល់សហព្រះរាជអាជ្ញាណាម្នាក់ ក្នុងចំណោមសហព្រះរាជអាជ្ញាទាំងពីររូប ឲ្យស្ថិតក្នុងស្ថានភាពក្រោមបង្គាប់របស់សហព្រះរាជអាជ្ញាណាម្នាក់ទៀត ត្រូវតែជៀសវាងឲ្យបានជាដាច់ខាត។

---

[38] **F9**, កថាខណ្ឌ ២១។

## III. ដំណោះស្រាយដែលស្នើសុំ

30. អាស្រ័យមូលហេតុដូចបានជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើអង្គជំនុំជម្រះ៖

i. កំណត់យក ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០១៥ ជាកាលបរិច្ឆេទចុងក្រោយ សម្រាប់ដាក់ចម្លើយតបរួម; និង

ii. កំណត់ថា ចម្លើយតបរួមត្រូវកំហិតត្រឹម ៤៦០ទំព័រ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៥ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក Nicholas KOUMJIAN**<br>សហព្រះរាជអាជ្ញា | | |